# របាយការណ៍ប្រចាំខែមីនា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

**១. សេចក្តីផ្តើម**

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

**២. ស្ថានភាពរបស់មន្ទីរ**

**២.១ ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៤ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

**២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ**

- ថ្ងៃទី ២៧ ខែកុម្ភៈ លោកអនុប្រធានមន្ទីរចូលរួមទិវាទីក្រុងស្អាត លើកទី ៤ ក្រោមប្រធានបទ ទីក្រុងខ្ញុំស្អាត សុខសុវត្ថិភាពល្អ ទេសចរណ៍មានកំណើន នៅបរិវេណច្រកអន្តរជាតិអូរស្មាច់
- ថ្ងៃទី ២៧ ខែកុម្ភៈ លោកប្រធានមន្ទីរចូលរួមកិច្ចប្រជុំត្រៀមទទួលបដិសណ្ឋារកិច្ច និងផែនការការពារសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន នៅសណ្ឋាគារ និងកាស៊ីណូសាង៉ារីសត
- ថ្ងៃទី២៨ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ ចូលរួមក្នុងពិធីសម្ពោធសមិទ្ធផលឆ្លងក្លោងទ្វារ និងរបងវត្តរស្មីជ័យឧត្តមបេង នៅឃុំបេង ស្រុកបន្ទាយអំពិល
- ថ្ងៃទី ២៩ ខែកុម្ភៈ លោកប្រធានមន្ទីរ ចូលរួមប្រជុំក្រុមការងារថ្នាក់ជាតិប្រចាំខែមករា-កុម្ភៈ ឆ្នាំ ២០១៦ និងទិសដៅអនុវត្តបន្ត ក្រោមអធិបតីភាព ឯកឧត្តម **គន់ គីម** ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្ត
- ថ្ងៃទី ០២ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមប្រជុំជាមួយគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ដើម្បីស្វែងយល់ពីការអនុវត្តច្បាប់ និងវិស័យយុត្តិធម៌ នៅសាលប្រជុំធំសាលាខេត្ត
- ថ្ងៃទី ០៣ ខែមីនា លោកប្រធានមន្ទីរ ចូលរួមកម្មវិធីជួបជុំពិសារអាហារសាមគ្គី ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិ ០៨ មីនា ឆ្នាំ ២០១៦ ខួបលើកទី ១០៥ ក្រោមអធិបតីភាព **ឯកឧត្តម ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ នៅភោជនីយដ្ឋានទន្លេបាសាក់ ២ រាជធានីភ្នំពេញ
- ថ្ងៃទី ០៣ ខែមីនា លោកអនុប្រធានមន្ទីរ និងលោកអនុប្រធានការិយាល័យផ្លូវជនបទ ចូលរួមកម្មវិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១០៥ ឆ្នាំ ២០១៦ ក្រោមប្រធានបទ វិនិយោគ

លើសមភាពយេនឌ័រ ដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលាស្រុកអន្លង់វែង

- ថ្ងៃទី ០៤ ខែមីនា លោកអនុប្រធានមន្ទីរ កិច្ចប្រជុំក្រុមការងារពិសេសថ្នាក់ខេត្តសម្រាប់លុបបំបាត់ជម្ងឺគ្រុនចាញ់ខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **លៀម សុជា** អភិបាលរងខេត្ត នៅមន្ទីរសុខាភិបាលខេត្ត
- ថ្ងៃទី ០៧ ខែមីនា លោកអនុប្រធានមន្ទីរ និងអនុប្រធានការិយាល័យរដ្ឋបាល ចូលរួមប្រជុំពិភាក្សាលើការរៀបចំបញ្ជីរាយនាមមន្ត្រីរាជការការដែលត្រូវដំឡើងថ្នាក់ ការជ្រើសរើសមន្ត្រីរាជការក្របខណ្ឌឆ្នាំ ២០១៦ និងការគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ១០ ខែមីនា លោកប្រធានមន្ទីរ និងលោកអនុប្រធានមន្ទីរ ០២ រូប ចូលរួមក្នុងពិធីចែកអំណោយមនុស្សធម៌ដល់ចាស់ជរាគ្មានទីពឹង អ្នកផ្ទុក និងអ្នកជម្ងឺអេដស៍ ជនពិការ ក្មេងកំព្រាមេម៉ាយទីទ័លក្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** នៅភូមិទួលត្បែង ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង
- ថ្ងៃទី ១១ ខែមីនា លោកប្រធានមន្ទីរ និងលោកអនុប្រធានមន្ទីរ ០២ រូប ចូលរួមក្នុងពិធីចែកអំណោយមនុស្សធម៌ដល់ចាស់ជរាគ្មានទីពឹង អ្នកផ្ទុក និងអ្នកជម្ងឺអេដស៍ ជនពិការ ក្មេងកំព្រាមេម៉ាយទីទ័លក្រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** នៅភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង
- ថ្ងៃទី ១៤ ខែមីនា លោកប្រធានមន្ទីរ ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ២២ របស់ក្រុមប្រឹក្សាខេត្តឆ្នាំទី ២ អាណត្តិទី ២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំធំសាលាខេត្ត
- ថ្ងៃទី ១៥ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមសន្និបាតរបស់សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត ប្រចាំឆ្នាំ ២០១៥ និងកិច្ចពិភាក្សាការអនុវត្តច្បាប់ជាមួយមន្ត្រីនគរបាលយុត្តិធម៌ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសណ្ឋាគារឈើនប្រាក់កប ខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១៧ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមពិធីអបអរសាទរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៨ ឆ្នាំ ២០១៦ ក្រោមអធិបតីភាពឯកឧត្តម **គង់ គន្ធារ៉ា** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលប្រជុំមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត
- ថ្ងៃទី ២១ ខែមីនា លោកអនុប្រធានមន្ទីរ ចូលរួមពិធីប្រកាសតែងតាំងមុខតំណែងប្រធានមន្ទីរកសិកម្មខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសាលប្រជុំសាលាខេត្ត

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះរកទីតាំងគ្រួសក្រហមផ្គត់ផ្គង់ខ្សែផ្លូវ ពីភូមិគោកធ្នង់ ដល់ភូមិគោកត្រាង ឃុំជើនទៀន ស្រុកចុងកាល់ មានប្រវែងសរុប ៨ ០០០ ម៉ែត្រ និងផ្លូវ ០១ ខ្សែទៀត នៅសង្កាត់កូនក្រៀល ក្រុងសំរោង មានប្រវែងសរុប ៧ ៥០០ ម៉ែត្រ
- ថ្ងៃទី ១០ ខែកុម្ភៈ ចុះត្រួតពិនិត្យ និងសិក្សាគម្រោងផ្លូវជួសជុលបន្ទាន់ចាប់ផ្តើមពីភូមិគោកខ្ពស់ ដល់ភូមិថ្មល់ ឃុំគោកខ្ពស់ ស្រុកបន្ទាយអំពិល សរុបប្រវែង ៣ ៥០០ ម៉ែត្រ
- ថ្ងៃទី០៧-០៩ ខែមីនា ចុះធ្វើផ្លាកផ្លូវគម្រោងថែទាំខួប ២០១៥ និងចាក់គ្រួសបំពេញក្បាលលូ
- ថ្ងៃទី ១៥ ខែមីនា លោកប្រធានមន្ទីរ អមដំណើរគណៈប្រតិភូមកពីក្រសួងដឹកនាំដោយ ឯកឧត្តម **អ៊ុន ចន្ថា** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ចុះត្រួតពិនិត្យខ្សែខ្លូវថែទាំលក្ខណៈខួបឆ្នាំ ២០១៥ ដើម្បីបញ្ចប់សុពលភាព និង
- ថ្ងៃទី ១៦-១៧ ខែមីនា ចុះសិក្សា ត្រួតពិនិត្យខ្សែផ្លូវចាប់ពីភូមិគោកស្ពាន ដល់ភូមិរលំវែង ឃុំក្រសាំង ស្រុកចុងកាល់ មានប្រវែងសរុប ៣ ០៧០ ម៉ែត្រ ក្នុងនោះស្ពានត្រូវសាងសង់ថ្មី ចំនួន ០៤កន្លែង និងសាងសង់លូថ្មី ចំនួន ០៦ កន្លែង។

**៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត**

- ថ្ងៃទី ១៥ ខែកុម្ភៈ ប្រធានការិយាល័យ និងមន្រ្តីការិយាល័យ ០១ រូប ចុះប្រជុំជ្រើសរើសទីតាំងសាងសង់អណ្តូងស្នប់អាហ្វ្រីដេវថ្មីចំនួន ០២ កន្លែង មានទីតាំងនៅភូមិពុរ ០១ កន្លែង និងភូមិបុរីរដ្ឋបាល ០១ កន្លែង និងជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុល ០២ អណ្តូងនៅភូមិគោកជ្រេសសង្កាត់សំរោងក្រុងសំរោង
- ថ្ងៃទី ១៥-១៧ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ និងអនុប្រធានការិយាល័យ ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់ចំនួន ០៨ អណ្តូង និងជ្រើសរើសគ្រួសារសម្រាប់ចែកចាយធុងចម្រុះ ១០០ គ្រួសារ នៅភូមិខ្នាចឬស្សី ០២ អណ្តូង និងធុងចម្រុះ ៥០ គ្រួសារភូមិគោកចាន់រី ០២ អណ្តូង និងធុងចម្រុះ ៥០ គ្រួសារ សង្កាត់បន្សាយរាក់ ភូមិឈើក្រំ ០២ អណ្តូង និងភូមិបុស្សថ្មី ០២ អណ្តូង សង្កាត់កូនក្រៀល ក្រុងសំរោង
- ថ្ងៃទី ១៦ ខែកុម្ភៈ ប្រធានការិយាល័យ និងមន្រ្តីការិយាល័យ ០១ រូប ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុល ០៤ អណ្តូង នៅភូមិកណ្តែក ០២ អណ្តូង និងភូមិគោកចំបក់ ០២ អណ្តូង សង្កាត់សំរោងក្រុងសំរោង
- ថ្ងៃទី ១៧ ខែកុម្ភៈ ប្រធានការិយាល័យ និងមន្រ្តីការិយាល័យ ០១ រូប ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុល ០៤ អណ្តូង នៅភូមិត្របែក ០៣ អណ្តូង និងភូមិភ្លង់ចាស់ ០១ អណ្តូង សង្កាត់បុស្សស្បូវក្រុងសំរោង
- ថ្ងៃទី ១៨-១៩ ខែកុម្ភៈ ប្រធានការិយាល័យ និងមន្រ្តីការិយាល័យ ០១ រូប ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវថ្មីចំនួន ០៦ អណ្តូង នៅភូមិគោកវត្ត ០១ អណ្តូង ភូមិបន្ទាយចាស់ ០១

អណ្តូង ឃុំចុងកាល់ភូមិសែនមនោរម្យ ១ ចំនួន ០២ អណ្តូង និងភូមិសែនមនោរម្យ ២ ចំនួន ០២ អណ្តូង ឃុំគោកខ្ពស់

- ថ្ងៃទី ២២ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ និងអនុប្រធានការិយាល័យ ចុះប្រជុំជ្រើសរើសទីតាំងស្រះសហគមន៍ ០១ កន្លែងទំហំ (៤០មX៣០មX៣ម) នៅភូមិអូរវិជ្ជួលឃុំបេងស្រុកបន្ទាយអំពិល
- ថ្ងៃទី ២៣ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ និងអនុប្រធានការិយាល័យ ចុះប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវចំនួន ០១ អណ្តូងភូមិថ្នល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង និង
- ថ្ងៃទី ២៩ ខែកុម្ភៈ ដល់ថ្ងៃទី ០៨ ខែមីនា លោកអនុប្រធានមន្ទីរ និងអនុប្រធានការិយាល័យ ចុះត្រួតពិនិត្យការងារសាងសង់ស្រះសហគមន៍ ០១ កន្លែងទំហំ (៤០មX៣០មX៣ម) នៅភូមិអូរវិជ្ជួលឃុំបេងស្រុកបន្ទាយអំពិល សម្រេចបានលទ្ធផល ១០០% ឧបត្ថម្ភថវិកាដោយក្រសួងអភិវឌ្ឍន៍ជនបទ។

## ៣.៣ ការងារថែទាំសុខភាពជនបទ

- លោកអនុប្រធានការិយាល័យ និងមន្ត្រីការិយាល័យទឹកស្អាត ០១ រូប ចុះសិក្សា និងប្រមូលទិន្នន័យបង្គន់អនាម័យក្នុងភូមិគោលដៅ ១២ ភូមិ ០៣ ឃុំ ក្នុងស្រុកចុងកាល់ សម្រាប់គម្រោងឧបត្ថម្ភធនសម្ភារៈសាងសង់បង្គន់អនាម័យនៅតាមគ្រួសារចំនួន ៣០៣ បង្គន់ ជាផែនការឆ្នាំ ២០១៦ ។ ដោយមានការចូលរួមពីអាជ្ញាធរភូមិ និងប្រជាពលរដ្ឋសរុប ចំនួន ២៦១ នាក់ ស្ត្រីចំនួន ១៤៤ នាក់ ហើយជាលទ្ធផល សម្រេចបានមានដូចខាងក្រោម÷
    - ប្រជាពលរដ្ឋសរុបចំនួន ៦ ៨៨២ នាក់ ស្ត្រីចំនួន ៣ ៣៥៥ នាក់
    - គ្រួសារសរុបចំនួន ១៤៤០ គ្រួសារ
    - ខ្នងផ្ទះសរុបចំនួន ១២៦០ ខ្នង
    - ខ្នងផ្ទះមានបង្គន់ប្រើប្រាស់ ៦៤០ ខ្នង
    - ខ្នងផ្ទះគ្មានបង្គន់ប្រើប្រាស់ ៦២០ ខ្នង
    - ខ្នងផ្ទះទម្លាប់លាងសម្អាតដៃជាមួយនឹងសាប៊ូ ៦១៧ ខ្នង
    - ខ្នងផ្ទះមិនទម្លាប់លាងសម្អាតដៃ ៦៤៣ ខ្នង
    - ខ្នងផ្ទះប្រើប្រាស់ទឹកស្អាត ៨៧៧ ខ្នង (ដាំពុះ ២៤៨ ខ្នង និងទឹកចម្រោះ ៦២៩ ខ្នង)
    - ខ្នងផ្ទះប្រើប្រាស់ទឹកឆៅ ៣៨៣ ខ្នង
    - ចំនួនស្ថាប័នកំពុងគាំទ្រក្នុងភូមិ ០៣ ស្ថាប័ន (PDRD, CHHRA, iDE )
- លោកអនុប្រធានការិយាល័យ សហការជាមួយមន្ត្រីនាយកដ្ឋាន ដើម្បីចុះសិក្សា និងវាយតម្លៃពីការប្រតិបត្តិអនុវត្តអនាម័យរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ជនបទ ក្នុងភូមិគោលដៅចំនួន ០២ ភូមិ ០២ ឃុំ និង ០២ ស្រុក ស្មើនឹង ៥១ គ្រួសារ គឺភូមិសាលារាំង ឃុំគោកមន ស្រុកបន្ទាយអំពិល ២៤ គ្រួសារ និងភូមិចំការចេក សង្កាត់អូរស្មាច់ ក្រុងសំរោង មាន ២៧គ្រួសារ ជាលទ្ធផល

ឃើញថា÷

- ប្រជាពលរដ្ឋចំនួន ៦៥ % មានបង្គន់ប្រើប្រាស់
- ប្រជាពលរដ្ឋចំនួន ១០ % បានប្រើប្រាស់បង្គន់រួម
- ប្រជាពលរដ្ឋចំនួន ៣០ % ទម្លាប់បន្ទោបង់ពាសវាលពាសកាល
- ប្រជាពលរដ្ឋចំនួន ៥០ % បានទម្លាប់ប្រើប្រាស់ និងផឹកទឹកស្អាតជាប្រចាំ
- ប្រជាពលរដ្ឋចំនួន ៥០ % បានទម្លាប់ប្រើប្រាស់ និងផឹកទឹកមិនស្អាត
- ប្រជាពលរដ្ឋចំនួន ៦0% បានទម្លាប់អនុវត្តការលាងសម្អាតដៃជាមួយនឹងសាប៊ូជាប្រចាំ
- ប្រជាពលរដ្ឋចំនួន ៣៥ % បានទម្លាប់អនុវត្តការលាងសម្អាតជាមួយនឹងទឹកទទេ
- ប្រជាពលរដ្ឋចំនួន ៥ % បានទម្លាប់មិនលាងសម្អាតដៃមុនពេលបរិភោគអាហារ
- ប្រជាពលរដ្ឋចំនួន ៨៥ % មានការយល់ដឹងពីអនាម័យ
- ប្រជាពលរដ្ឋចំនួន ១៥ % មិនបានទទួលការអប់រំពីអនាម័យ

- មន្ត្រីការិយាល័យ ០២ រូប ចុះធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញលើភូមិដែលបានបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលទាំងស្រុងលើ ភូមិគោលដៅចំនួន ០៨ ភូមិ ស្ថិតក្នុងស្រុកចុងកាល់ ឃុំពង្រ មាន ០៣ ភូមិ និងក្រុងសំរោង សង្កាត់សំរោង មាន ០៥ ភូមិ ។ មានការចូលរួមសហការពីអាជ្ញាធរឃុំ ភូមិ និងប្រជាពលរដ្ឋ សរុបចំនួន ៧៥៦ នាក់ ស្ត្រី ៣៧១ នាក់ ក្នុងនោះកុមារចំនួន ១៣៤ នាក់ ។ ជាលទ្ធផល មានភូមិចំនួន ០៦ បានក្លាយទៅជាភូមិ ODF (ភូមិព្រៃនគរ ភូមិបន្ទាយជ័រ ឃុំពង្រ និងភូមិអូរឬស្សី ភូមិក្រវ៉ាន់ ភូមិដូនកែន ភូមិឈូក)។

### ៣.៤ ការងារអភិវឌ្ឍន៍សហគមន៍

សហការជាមួយអង្គការ FH Cambodia ចុះសម្របសម្រួល និងជ្រើសរើសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន ០៨ភូមិ គឺភូមិត្រពាំងប្រិយ៍ ភូមិទួលប្រសើរ ភូមិសុខសេរី ភូមិសំបូរ ភូមិទំនប់ថ្មី ភូមិស្រែល្អ ភូមិអូរគ្រោច និងភូមិមានជ័យ។

### ៣.៥ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

#### ៣.៥.១ ការងារសាងសង់ផ្ទះ

- ភូមិតាមាន់សែនជ័យ÷ បានសាងសរុបផ្ទះចំនួន ៣៩ ខ្នង
  - ផ្ទះសាងសង់សម្រេចបាន ១00% ចំនួន ៣២ ខ្នង
  - ផ្ទះសាងសង់សម្រេចបាន ៤0% ចំនួន ០៥ ខ្នង
  - ផ្ទះសាងសង់សម្រេចបាន ៣0% ចំនួន ០២ ខ្នង។

### ៣.៦ ការិយាល័យស្រុក/ក្រុង

- លោកប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុកចុងកាល់ ចូលរួមក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ រួមមាន÷

- ចុះសិក្សាផ្លូវគោកស្ពាន នៅរលំវែង មានប្រវែងសរុប ៣២៧០ ម៉ែត្រ ស្ពាន៤កន្លែង លូ ៦ កន្លែង
- ចូលរួមយុទ្ធនាការផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មី នៅវត្តចុងកាល់
- ចុះយកទីតាំងអណ្តូងស្នប់នៅមណ្ឌលសុខភាពចុងកាល់ និងការិយាល័យអប់រំ ស្រុកចុងកាល់
- ចូលរួមប្រជុំទទួលផែនការក្នុងមួយថ្ងៃមានសកម្មភាពអ្វីត្រូវផ្តល់ព័ត៌មានមកសាលាស្រុក ចុងកាល់
- ចូលរួមវេទិកាសាធារណៈ និងចែកអត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋ នៅឃុំចុងកាល់ និង ឃុំក្រសាំង
- ចូលរួមប្រជុំប្រចាំខែ របស់គណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារ នៅសាលាស្រុកចុងកាល់
- ចូលរួមប្រជុំប្រចាំខែ របស់ក្រុមប្រឹក្សាស្រុកចុងកាល់ លើកទី២១ អាណត្តិទី២
- ចុះយកចំនួនស្រះសហគមន៍ទឹកស្អាត ប្រើប្រាស់មិនកើត នៅតាមឃុំ ស្រុកចុងកាល់។

## ៤. ទិសដៅការងារបន្ត

- ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវសម្រាប់ជួសជុលចំនួន ១០ អណ្តូង
- សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ ធុង
- ចុះត្រួតពិនិត្យ និងសិក្សាផ្លូវជួសជុលបន្ទាន់ និងសាងសង់ថ្មី ទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- ចុះប្រមូលទិន្នន័យខ្សែផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាព សម្រាប់ឆ្នាំ ២០១៦
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវចំនួន ១៧ អណ្តូង
- បន្តការសហការជាមួយអង្គការដៃគូ ដើម្បីចុះពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ( គ.អ.ភ) នៅតាម ភូមិគោលដៅ។